# សេចក្តីមិនប្រមាទ



រៀបរៀងដោយ

**ភិក្ខុចិន ភេន ឥន្ទប្បញ្ញោ**

វត្តពោធិវង្ស ប្រទេសបារាំង

ព.ស.២៥៤៥ គ.ស.២០០១

# អារម្ភកថា

ពុទ្ធវចនៈ ពាក្យប្រៀប្រដៅរបស់ព្រះពុទ្ធមានច្រើនណាស់ លោកពោលថា មានដល់ទៅ ៨៤,០០០ ព្រះធម្មក្ខន្ធ ។ ប៉ុន្តែ ពាក្យមួយដែលព្រះពុទ្ធទ្រង់សម្តែងក្រោយបំផុត គឺ អប្បមាទៈ ប្រែថា សេចក្តីមិនប្រមាទ ។ សេចក្តីមិនប្រមាទ ជាកំពូលនៃកុសលធម៌ទាំងឡាយ កុសលធម៌ទាំងឡាយ តែងប្រជុំចុះក្នុងសេចក្តីមិនប្រមាទ ។ កាលបើសេចក្តីមិនប្រមាទកើតឡើងហើយ កុសលធម៌ទាំងឡាយ ដែលមិនទាន់កើត រមែងកើតឡើងផង អកុសលធម៌ទាំងឡាយដែលកើតឡើងហើយ រមែងសាបសូន្យ ទៅវិញផង ។

ដោយឃើញថា អត្ថន័យដ៏មានខ្លឹមសារ និងធំធេង ដូចនេះ ទើបខ្ញុំដកស្រង់យកព្រះធម៌នោះមក រៀបរៀងទុកជូនលោកអ្នកសិក្សាបដិបត្តិ ។ ខ្ញុំជឿថាលោកអ្នក នឹងបានប្រយោជន៍ច្រើនពីការបដិបត្តិ តាមព្រះធម៌នេះ ។

វត្តពោធិវង្ស, ថ្ងៃទី ៨ ខែតុលា ឆ្នាំ២០០១

**ភិក្ខុ ជិន ភេន ឥន្ទប្បញ្ញោ**

---

នូវរាល់កំហុសឆ្គងដែលកើតឡើងពីការវាយពុម្ភអក្សរនេះ សូមអស់លោកអ្នកជួយកែលម្អដើម្បីឲ្យបាន ត្រឹមត្រូវ និង ល្អប្រសើរឡើងវិញផង ។ អរគុណ !!!

នគរបឋម, ថ្ងៃ២៨ ខែមីនា ឆ្នាំ២០១៣

អគ្គធរោ អ៊ុំម ឧត្តម
udom_student@hotmail.com

# នមត្ថុ រតនត្តយស្ស

## អប្បមាទេន សម្បាទេថ

*អ្នកទាំងឡាយ ចូរញ៉ាំងសេចក្តីមិនប្រមាទឲ្យកើតឡើងដោយប្រពៃចុះ*[1]។

**អប្បមាទ** ពាក្យថាមិនប្រមាទ ឬកុំប្រមាទ នេះជាបច្ឆឹមវាចាគឺជាព្រះវាចាចុងក្រោយបំផុតរបស់ព្រះពុទ្ធ បានសេចក្តីថា ព្រះពុទ្ធទ្រង់ត្រាស់ពាក្យនេះហើយលែងមានព្រះពុទ្ធដីកាអ្វីទៀតទាំងអស់រហូតដល់ពេលបរិនិព្វាន ។ ពាក្យចុងក្រោយបំផុតយ៉ាងនេះ បើតាមទម្លាប់របស់អ្នកស្រុកគេថាជាពាក្យបណ្តាំ ជាពាក្យផ្តាំផ្ញើ ជាពាក្យមានខ្លឹមសារ សំខាន់បំផុតហើយ ។ ចំណែកព្រះពុទ្ធសាសនា មិនបានកំណត់ទុកថាអ្វីៗ ដែលក្រោយបំផុត សុទ្ធតែល្អនោះទេ គេត្រូវពិចារណាឲ្យម៉ត់ចត់សិន សឹមឲ្យតម្លៃទៅតាមសាច់រឿងនោះ ៗ ។ ចំពោះព្រះពុទ្ធ ព្រះអង្គទ្រង់សម្តែងធម៌សំខាន់ ៗ សម្តែងសច្ចធម៌រៀងរហូតមកហើយពាក្យថាមិនប្រមាទនេះ ព្រះអង្គបានសម្តែងញឹកញាប់ណាស់ ប៉ុន្តែបើយើងយកពាក្យនេះទៅពិនិត្យមើលតាមទម្លាប់របស់អ្នកស្រុក ក៏នឹងឃើញថាសមស្របគ្នាមែន ព្រោះពាក្យនេះមានខ្លឹមសារសំខាន់ណាស់ ។ ហេតុនេះ យើងជាពុទ្ធសាសនិកត្រូវតែសិក្សា និងបដិបត្តិតាម ព្រះបច្ឆឹមវាចានេះឲ្យបានម៉ត់ចត់ត្រឹមត្រូវល្អ ។

ដើម្បីឲ្យងាយយល់ថា មិនប្រមាទមានខ្លឹមសារយ៉ាងណា យើងត្រូវយកពាក្យ ២ គឺ **បមាទ** ប្រែថា ប្រមាទ និង **អប្បមាទ** ប្រែថា មិនប្រមាទ មកប្រៀបធៀបគ្នាមើល តើមានអត្ថន័យប្លែកគ្នាយ៉ាងម៉េច ?

**បមាទ** គឺ ៖

*១-ការប្រហែសធ្វេស ការបណ្តែតបណ្តោយ ការបង្អែបង្អង់*

*ការមិនយកចិត្តទុកដាក់-ល- ។*

*២-សេចក្តីស្រវឹង ។*

*៣-កង្វះសតិ ។*

**អប្បមាទ** គឺ ៖

*១-ការមិនប្រហែសធ្វេស ការមិនបណ្តែតបណ្តោយ ការមិនបង្អែបង្អង់*

*ការយកចិត្តទុកដាក់-ល- ។*

*២-សេចក្តីមិនស្រវឹង ។*

[1] អ្នកខ្លះប្រែថា ចូរញ៉ាំងកិច្ចទាំងពួងឲ្យសម្រេចដោយសេចក្តីមិនប្រមាទចុះ។

*៣-ការមានសតិគ្រប់កាល។*

## អត្ថាធិប្បាយ

១-យើងមានទ្រព្យសម្បត្តិ បើយើងប្រហែសធ្វេស មិនប្រុងប្រយ័ត្ន មិនទុកដាក់ឲ្យល្អ ទ្រព្យសម្បត្តិនោះ នឹងវិនាសអន្តរាយ ទើបមានពាក្យចាស់លោកពោលថា ប្រហែសបាត់ ប្រយ័ត្នគង់ ។ យើងបើករថយន្ត បើយើងបររថយន្ត បើយើងប្រហែស នឹងមានគ្រោះថ្នាក់ច្រើន បើយើងប្រុងប្រយ័ត្ន អាចនឹងផុតពីគ្រោះថ្នាក់បាន ឬសូម្បីមានខ្លះក៏តិចជាង ។ យើងមានកូនចៅ បើយើងបណ្ដែតបណ្ដោយ ពេកយើងមិនសូវមានសង្ឃឹមថាវាមានអនាគតល្អទេ... ។ ធ្វើការងារអ្វី បើយើងបង្អែបង្អង់ រវល់តែចាំអីចេះ ចាំអីចុះ ចាំពេលនេះអី ចាំពេលនោះ យើងទៅមិនទាន់សភាពការណ៍ទេ សូម្បីយើងមិនបង្អែបង្អង់ក៏ដោយ បើយើងធ្វើការដោយមិនយកចិត្តទុកដាក់ ការងារនោះក៏មិនបានសម្រេចលទ្ធផលល្អដែរ ។

២-សេចក្ដីស្រវឹងមានច្រើនណាស់ ក្នុងគម្ពីរសម្មោហវិនោទនីពោលថាមាន ២៦ យ៉ាង យើងមិនចាំបាច់រៀនឲ្យចេះទាំងអស់គ្រប់គ្នាទេ ចេះតែល្មមបដិបត្តិក៏បានដែរ រឿងស្រវឹងនេះ ទោះបីស្រវឹងអីក៏ដោយសុទ្ធតែមិនល្អទាំងអស់ ។ ស្រវឹងស្រី ស្រវឹងស្រា ស្រវឹងល្បែងពាលាកំពុងពេញនិយមហើយ ទីណាក៏ដូចជាទីណា ព្រះធម៌មិនងាយជ្រៀតចូលចុះទេ ។ សព្វថ្ងៃនៅស្រុកយើង សម្បើមយក្សហើយ ស្រវឹងយសសក្តិ ស្រវឹងអំណាច ស្រវឹងជាតិត្រកូល ស្រវឹងចំណេះវិជ្ជា ស្រវឹងទ្រព្យសម្បត្តិ ស្រវឹងខ្ញុំកំដរ បរិវារឆ្វេងស្ដាំ មកដល់សម័យនេះហើយ គ្មានភ្ញាក់ខ្លួនសោះសប្បាយនឹងយកគេមកធ្វើខ្ញុំកំដរខ្លួន បើតាមសម្ដីពួកគេថាមានមេត្តា ករុណា ច្រើនណាស់ តែខ្ញុំកំដរវាចេះតែខិលខូច អនិច្ចា អើយ...។

*ក្នុងអភិណ្ហបច្ចវេក្ខណៈព្រះពុទ្ធទ្រង់សម្ដែងនូវសេចក្ដីស្រវឹង៣ ប្រការគឺ ៖*

១-**យោព្វនមទ** ស្រវឹងវ័យ គិតថាអញនៅក្មេងត្រូវតែលេងអ្វីឲ្យសប្បាយ ។

២-**អារោគ្យមទ** ស្រវឹងថាអញមិនមានរោគនៅមានសុខភាពល្អណាស់ ត្រូវសប្បាយឲ្យអស់ចិត្តសិន ។

៣-**ជីវិតមទ** ស្រវឹងជីវិត គិតថាអញនៅមានជីវិតរស់នៅវែងតទៀត កុំអាលធ្វើបុណ្យកុសលអីចាំចាស់ទៅធ្វើឲ្យមែនទែនតែម្ដង ។

កាលបើគេមានសេចក្ដីស្រវឹងនេះហើយ មានតែសេចក្ដីប្រមាទនិងបាបអកុសលតែប៉ុណ្ណោះដែលអាចកើតឡើងបាន គេថាចាំចាស់ទៅ នឹងធ្វើបុណ្យកុសលឲ្យមែនទែនតែម្ដង ធ្វើបានតែម្ដងក៏មានជួនកាលមិនទាំងបានធ្វើម្ដងផងក៏មានដែរ ។ ព្រោះហេតុនេះ ទើបព្រះសម្មាសម្ពុទ្ធសម្ដែងធម៌ឲ្យពួកគេបន្ទោបង់សេចក្ដីស្រវឹងនោះ ដោយការពិចារណារឿយៗ ថា **ជរាធម្មោម្ហិ ជរំ អនតីតោ** *អាត្មាអញមានជរាជាធម្មតា មិនកន្លងជរាទៅបានឡើយ* **ព្យាធិធម្មោម្ហិ ព្យាធឹ អនតីតោ** *អាត្មាអញមាន*

*រោគាព្យាធិជាធម្មតា មិនកន្លងរោគាព្យាធិទៅបានឡើយ* មរណធម្មម្ហិ មរណំ អនតីតោ *អាត្មាអញមានសេចក្តីស្លាប់ជាធម្មតាមិនកន្លងសេចក្តីស្លាប់ទៅបានឡើយ។*

ហួសពីនេះទៅទៀត បុគ្គលខ្លះចេញចាកផ្ទះទៅស្វែងរកធម៌ ប៉ុន្តែនៅស្រវឹងលាភសក្ការៈ យសសក្តិ ទាន សីល ភាវនា ក៏មាន ធ្វើអ្វីៗតាមខ្លួនឯងចេះ តាមខ្លួនឯងចង់សំគាល់ថាខ្លួនឯងត្រូវ អ្នកឯទៀតខុស មិនព្រមសិក្សាមើល គម្ពីរ ដីកា ឲ្យបានម៉ត់ចត់ត្រឹមត្រូវទេ ធ្វើតាមខ្លួនឯង ឬ ធ្វើតាមព្រះពុទ្ធ ?

៣-កង្វះសតិ សតិ ធម៌សម្រាប់ធ្វើចិត្តឲ្យភ្ញាក់រឭកសម្រាប់ទប់ចិត្តកុំឲ្យរត់ចោលការ សម្បជញ្ញៈ ធម៌សម្រាប់ធ្វើចិត្តឲ្យដឹងខ្លួនថាកំពុងធ្វើអ្វី ធ្វើដោយវិធីយ៉ាងម៉េច ។ ធម៌ ២ យ៉ាងនេះទៅមកជាមួយគ្នា បើមានសតិ សម្បជញ្ញ ក៏មានដែរ បើខ្វះសតិ សម្បជញ្ញកើតឡើងមិនបានទេ សតិ សម្បជញ្ញ ជាធម៌មាន ឧបការៈ (ប្រយោជន៍) ច្រើនណាស់ ត្រូវប្រើទាំងផ្លូវលោក ទាំងផ្លូវធម៌ បើខ្វះសតិហើយធ្វើអ្វីមានតែខុស ខូចខាត ខកខាន ជាដើម ។ បមាទ ប្រែថា ប្រមាទ គឺនៅប្រាសចាកសតិ បានសេចក្តីថា គ្មានសតិ ។ បុគ្គលអ្នកប្រមាទធ្វើការអ្វីមិនទាន់គេទេ ។

អប្បមត្តោ បមត្តេសុ សុត្តេសុ ពហុជាគរោ
អពលស្សំវ សីឃស្សោ ហិត្វា យាតិ សុមេធសោ[២] ។

*អ្នកមានប្រាជ្ញាកាលបើមនុស្សទាំងឡាយប្រមាទលោកមិនប្រមាទកាលបើ មនុស្សទាំងឡាយដេកលក់លោកភ្ញាក់រឭកច្រើន លោករមែងទៅចោលមនុស្ស បែបនោះ ដូចសេះដែលមានល្បឿនទៅចោលសេះមានកម្លាំងខ្សោយដូចនោះ ឯង ។*

ចំណែក អប្បមាទ មានអត្ថាធិប្បាយផ្ទុយគ្នាស្រឡះ ពី បមាទ ។ បើតាមអត្ថន័យជាន់ខ្ពស់ លោកពោលថា អ្នកមិនប្រមាទ គឺ អ្នកឈប់ធ្វើអំពើអាក្រក់ បើមិនទាន់ឈប់ ឈ្មោះថាអ្នកប្រមាទ ។ អ្នកប្រមាទចេះតែថយក្រោយទាបចុះៗ ឯអ្នកមិនប្រមាទចេះតែទៅមុខខ្ពស់ឡើងជាលំដាប់ ។

អព្យាបន្នោ សទា សតោ អជ្ឈត្តំ សុសមាហិតោ
អភិជ្ឈាវិនយេ សិក្ខំ អប្បមត្តោតិ វុច្ចតិ[៣]។

*បុគ្គលអ្នកមិនមានចិត្តព្យាបាទមានសតិគ្រប់កាលមានចិត្តតម្កល់មាំប្រព្រឹត្តទៅ ក្នុងខាងក្នុងសិក្សាក្នុងការបន្ទោសបង់នូវអភិជ្ឈាតថាគតហៅថាអ្នកមិនប្រមាទ។*

[២] *សុត្តន្តបិដក ខុទ្ទកនិកាយខុទ្ទកបាឋ ៥២/១២/២៧ ។*

[៣] *សុត្តន្តបិដក អង្គុត្តរនិកាយចតុក្កនិបាត៤២/១១៦/៣០១ ។*

# អ្នកមិនប្រមាទត្រូវបដិបត្តិដូចម្តេច ?

ព្រះពុទ្ធប្រៀនប្រដៅថា

ចតូហិ ភិក្ខវេ ឋានេហិ អប្បមាទោ ករណីយោ ។ កតមេហិ ឋានេហិ ។ កាយទុច្ចរិតំ ភិក្ខវេ បជហថ កាយសុចរិតំ ភាវេថ តត្ថ ច មា បមាទត្ថ ។ល។ មិច្ឆាទិដ្ឋឹ ភិក្ខវេ បជហថ សម្មាទិដ្ឋឹ ភាវេថ តត្ថ ច មា បមាទត្ថ[៤] ។

*ម្នាលភិក្ខុទាំងឡាយ បុគ្គលគប្បីធ្វើសេចក្តីមិនប្រមាទដោយហេតុ៤ យ៉ាង ។ ដោយហេតុ ៤ យ៉ាងតើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរលះបង់នូវកាយទុច្ចរិត វចីទុច្ចរិត មនោទុច្ចរិត មិច្ឆាទិដ្ឋិ ចូរចំរើននូវកាយសុចរិត វចីសុចរិត មនោសុចរិត សម្មាទិដ្ឋិ ចូរកុំប្រមាទក្នុងការលះនិងកុំប្រមាទក្នុងការចំរើននោះឡើយ។*

ចតូសុ ភិក្ខវេ ឋានេសុ អត្តរូបេន អប្បមាទោ សតិចេតសោ អារក្ខោ ករណីយោ ។ មា មេ រជនីយេសុ ធម្មេសុ ចិត្តំ រជ្ជីតិ អត្តរូបេន អប្បមាទោ សតិចេតសោ អារក្ខោ ករណីយោ ។ល។ មា មេ មទនីយេសុ ធម្មេសុ ចិត្តំ មជ្ជីតិ អត្តរូបេន អប្បមាទោ សតិចេតសោអារក្ខោ ករណីយោ[៥] ។

*ម្នាលភិក្ខុទាំងឡាយ សេចក្តីមិនប្រមាទ គឺការថែរក្សាចិត្តដោយសតិ បុគ្គលគប្បីធ្វើតាមសមគួរ ដល់ខ្លួន ក្នុងហេតុ ៤ យ៉ាង ។ ហេតុ ៤ យ៉ាងដូចម្តេចខ្លះ ។ គឺសេចក្តីមិនប្រមាទបានដល់ការថែរក្សាចិត្តដោយសតិ បុគ្គលគប្បីធ្វើតាមសមគួរដល់ខ្លួនថា ចិត្តរបស់អាត្មាអញកុំត្រេកត្រអាលក្នុងធម៌ទាំងឡាយដែលគួរត្រេកត្រអាលឡើយ ១ កុំប្រទូស្តក្នុងធម៌ទាំងឡាយដែលគួរប្រទូស្តឡើយ ១ កុំកាន់ច្រឡំក្នុងធម៌ទាំងឡាយដែលគួរកាន់ច្រឡំឡើយ១ កុំស្រវឹងក្នុងធម៌ទាំងឡាយដែលគួរស្រវឹង១ ។*

បុគ្គលអ្នកបានសិក្សា ហើយបានបដិបត្តិតាមពាក្យប្រៀនប្រដៅដែលស្រង់យកមកដោយសង្ខេបនេះ ឈ្មោះថា អ្នកមិនប្រមាទ ។ អ្នកមិនប្រមាទ រមែងបានទទួលផលប្រយោជន៍ច្រើន ទាំងក្នុងលោកនេះ ទាំងក្នុងបរលោក ពិសេសទៅទៀត នឹងបានសម្រេចព្រះនិព្វានជាក្សេមក្សាន្តចាកទុក្ខដោយប្រការទាំងពួង ។

ព្រះពុទ្ធសម្តែងថា ៖

អប្បមាទោ អមតំ បទំ បមាទោ មច្ចុនោ បទំ

---

[៤] *សុត្តន្តបិដក អង្គុត្តរនិកាយចតុក្កនិបាត៤២/១១៦/៣០១ ។*

[៥] *សុត្តន្តបិដក អង្គុត្តរនិកាយចតុក្កនិបាត៤២/១១៦/៣០២ ។*

**អប្បមត្តោ ន មីយន្តិ យេ បមត្តា យថា មតោ [៦] ។**

*សេចក្តីមិនប្រមាទ ជាផ្លូវនៃសេចក្តីមិនស្លាប់ សេចក្តីប្រមាទ ជាផ្លូវនៃសេចក្តីស្លាប់ ជនទាំងឡាយដែលមិនប្រមាទហើយ ឈ្មោះថាមិនស្លាប់ ជនទាំងឡាយដែលប្រមាទហើយ ទុកដូចជាស្លាប់ហើយ។*

អត្ថាធិប្បាយ ៖

សេចក្តីមិនប្រមាទ ជាផ្លូវនៃសេចក្តីមិនស្លាប់ ។ ជាផ្លូវគឺជាហេតុ បានសេចក្តីថា សេចក្តីមិនប្រមាទជាហេតុនៃសេចក្តីមិនស្លាប់ ។ មិនស្លាប់តាមន័យជាន់ទាប សំដៅយក ការរស់រីករុងរឿងឡើងក្នុងជីវិតប្រចាំថ្ងៃ តាមន័យជាន់ខ្ពស់ សំដៅយក ការធ្វើសេចក្តីល្អ ការបានសម្រេចព្រះនិព្វានជាទីក្សេមក្សាន្ត ឥតមានប្រែប្រួល ឥតមានស្លាប់ដែលហៅថា អមតៈ ។ សេចក្តីប្រមាទ ជាហេតុនៃសេចក្តីស្លាប់ ។ សេចក្តីស្លាប់តាមន័យជាន់ទាប សំដៅយក ការរេចរិលរៀវរោយអន់ថយចុះ ការស្លាប់សេចក្តីល្អ តាមន័យជាន់ខ្ពស់ សំដៅយកការកើតស្លាប់ រាប់ជាតិមិនអស់ រកព្រះនិព្វានមិនឃើញនៅតែវិលវល់ ។

អ្នកមិនប្រមាទ ឈ្មោះថាមិនស្លាប់ បានសេចក្តីថា សេចក្តីល្អរបស់គេមិនស្លាប់ ទាំងកិច្ចរបស់គេក៏រីកដុះដាលឡើងជាលំដាប់ សូម្បីរូបកាយរបស់គេស្លាប់ ប៉ុន្តែ កេរ្តិ៍ឈ្មោះរបស់គេស្ថិតនៅ គឺថា មិនស្លាប់ ។ ឯអ្នកប្រមាទ ទុកដូចជាស្លាប់ហើយ ព្រោះធ្វើល្អមិនកើត ធ្វើទានសីលក៏មិនកើត ដូចជាមនុស្សស្លាប់អីចឹង រស់តែដង្ហើម ប៉ុន្តែ សេចក្តីល្អស្លាប់ ។

ព្រះសម្មាពុទ្ធទ្រង់សម្តែងទោសនៃសេចក្តីប្រមាទ និងគុណនៃសេចក្តីមិនប្រមាទ ទុកជាច្រើន ដែលខ្ញុំបានដកស្រង់យកមកខ្លះគ្រាន់ជាឧទាហរណ៍ ៖

ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមើលមិនឃើញនូវធម៌ដទៃសូម្បីតែ ១ ដែលញ៉ាំងពួកអកុសលធម៌មិនទាន់កើតឲ្យកើតឡើងក្តី ញ៉ាំងពួកកុសលធម៌ដែលកើតឡើងហើយ ឲ្យសាបសូន្យទៅវិញក្តី ដូចសេចក្តីប្រមាទនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ កាលបើបុគ្គលប្រមាទហើយ ពួកអកុសលធម៌ដែលមិនទាន់កើតរមែងកើតឡើងផង ពួកកុសលធម៌ដែលកើតឡើងហើយ រមែងសាបសូន្យទៅវិញផង ។

ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមើលមិនឃើញនូវធម៌ដទៃសូម្បីតែ ១ ដែលញ៉ាំងកុសលធម៌មិនទាន់កើត ឲ្យកើតឡើងក្តី ញ៉ាំងពួកអកុសលធម៌ដែលកើតឡើងហើយ ឲ្យសាបសូន្យទៅវិញក្តី ដូចសេចក្តីមិនប្រមាទនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ កាលបើបុគ្គលមិនប្រមាទហើយ ពួកកុសលធម៌ដែលមិនទាន់កើត រមែងកើតឡើងផង ពួកអកុសលធម៌ដែលកើតឡើងហើយ រមែងសាបសូន្យទៅវិញផង ។

*សុត្តន្តបិដក អង្គុត្តរនិកាយឯកនិបាត៤០/៦០/៦១*

---

[៦] *សុត្តន្តបិដក ខុទ្ទកនិកាយខុទ្ទកបាឋទិ ៥២/១២/២៥ ។*

ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមើលមិនឃើញនូវធម៌ដទៃសូម្បីតែ ១ ដែលប្រព្រឹត្តទៅដើម្បីឲ្យខូចប្រយោជន៍ច្រើនដូចសេចក្តីប្រមាទនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ សេចក្តីប្រមាទប្រព្រឹត្តទៅដើម្បីឲ្យខូចប្រយោជន៍ច្រើន ។

*សុត្តន្តបិដក អង្គុត្តរនិកាយឯកនិបាត៤០/៨៣/៣០*

ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមើលមិនឃើញនូវធម៌ដទៃសូម្បីតែ ១ ដែលប្រព្រឹត្តទៅដើម្បីឲ្យបានប្រយោជន៍ច្រើនដូចសេចក្តីមិនប្រមាទនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ សេចក្តីមិនប្រមាទ ប្រព្រឹត្តទៅដើម្បីឲ្យបានប្រយោជន៍ច្រើន ។

*សុត្តន្តបិដក អង្គុត្តរនិកាយឯកនិបាត៤០/៨២/៣០*

ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមើលមិនឃើញនូវធម៌ដទៃសូម្បីតែ ១ ដែលប្រព្រឹត្តទៅដើម្បីវិនាស ដើម្បីអន្តរធាននៃព្រះសទ្ធម្ម ដូចសេចក្តីប្រមាទនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ សេចក្តីប្រមាទ ប្រព្រឹត្តទៅដើម្បីវិនាស ដើម្បីអន្តរធាន នៃ ព្រះសទ្ធម្ម ។

*សុត្តន្តបិដក អង្គុត្តរនិកាយឯកនិបាត៤០/១១៥/៣៨*

ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមើលមិនឃើញនូវធម៌ដទៃសូម្បីតែ ១ ដែលប្រព្រឹត្តទៅដើម្បីតាំងនៅ ដើម្បីមិនវិនាស ដើម្បីមិនអន្តរធាននៃព្រះសទ្ធម្ម ដូចសេចក្តីមិនប្រមាទនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ សេចក្តីមិនប្រមាទប្រព្រឹត្តទៅដើម្បីតាំងនៅ ដើម្បីមិនវិនាស ដើម្បីមិនអន្តរធាន នៃព្រះសទ្ធម្ម ។

*សុត្តន្តបិដក អង្គុត្តរនិកាយឯកនិបាត៤០/១១៦/៣៩*

ម្នាលភិក្ខុទាំងឡាយ ស្នាមជើងឯណានីមួយនៃសត្វដែលត្រាច់លើផែនដី ស្នាមជើងទាំងអស់នោះតែងដល់នូវការប្រកចុះក្នុងស្នាមជើងនៃដំរី ស្នាមជើងនៃដំរីប្រាកដជាប្រសើរជាង ស្នាមនៃពួកសត្វទាំងឡាយនោះ ព្រោះហេតុថា ស្នាមជើងនោះជាស្នាមជើងធំ យ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ កុសលធម៌ទាំងឡាយឯណានីមួយ កុសលធម៌ទាំងឡាយនោះ មានអប្បមាទជាមូល មានអប្បមាទជាទីប្រជុំចុះ អប្បមាទធម៌ប្រាកដជាប្រសើរជាងធម៌ទាំងនោះដែរ ។

*សុត្តន្តបិដក សំយុត្តនិកាយមហាវារវគ្គ៣៧/២៥៣/១១៦*

សេចក្តីបញ្ជាក់ ៖

ខ្ញុំមានបំណងនឹងលើកយកពាក្យ អប្បមាទៈ សេចក្តីមិនប្រមាទ (កុំប្រមាទ) ឲ្យលេចធ្លោឡើង ទើបខ្ញុំនិយាយតែអប្បមាទប៉ុណ្ណោះ ប៉ុន្តែ ក្រែងអស់លោក អ្នកខ្លះសង្ស័យខ្ញុំ សូមជម្រាបថា បច្ចឹមវាចាមាន ២ បាទ (ឃ្លា) គឺ *វយធម្មា សង្ខារា សង្ខារទាំងឡាយមានសេចក្តីសាបសូន្យជាធម្មតា*

*អប្បមាទេន សម្បាទេថ អ្នកទាំងឡាយ ចូរញុំាងកិច្ចទាំងពួងឲ្យសម្រេច ដោយសេចក្តីមិនប្រមាទចុះ*[៧]។

អត្ថាធិប្បាយ ៖ សង្ខារ គឺ អ្វីដែលអាស្រ័យហេតុបច្ច័យរួមផ្សំគ្នាកើតឡើង ជារូបធម៌មានចិត្ត មានវិញ្ញាណដូចជាមនុស្ស សត្វ ជាដើមក្តី ជារូបធម៌ដែរតែមិនមានចិត្ត មិនមានវិញ្ញាណដូចភ្នំដុំថ្ម ឬ សម្ភារៈប្រើប្រាស់ផ្សេងៗ ជាដើមក្តី ជានាមធម៌មិនមានរូបដូចជា វេទនា សញ្ញា វិញ្ញាណ ក្តី ។ ទាំងអស់នេះ លោកហៅថា សង្ខារ ។ សង្ខារមានសេចក្តីសាបសូន្យជាធម្មតា គឺ វាតែងតែប្រែប្រួលទៅ មិនគង់ធន់នៅដូចដើម និង រលត់រលាយទៅវិញជាធម្មតា តាមច្បាប់របស់ហេតុបច្ច័យ ឬ ថាតាមច្បាប់របស់ធម្មជាតិ ច្បាប់របស់សង្ខារ ច្បាប់របស់ព្រះត្រៃលក្ខណ៍ ។ មិនមាននរណា អាចទប់ឃាត់ ឬ បង្គាប់បញ្ជាវាឲ្យប្រព្រឹត្តទៅតាមអំណាចរបស់ខ្លួនបានឡើយ ។

ខ្លួនយើងក៏សង្ខារ កូន ប្រពន្ធ ប្តី យើងក៏សង្ខារ របស់ដែលយើងមាន យើងប្រើសប្រាស់ក៏សង្ខារ អ្វីទាំងអស់ដែលកើតមានក្នុងលោក ក៏សុទ្ធតែសង្ខារ គឺថា សង្ខាររស់នៅជាមួយសង្ខារ មិនទៀងរស់នៅជាមួយមិនទៀង... ដូចនេះ បើយើងប្រមាទ ប្រហែសធ្វេស មិនមានសតិប្រុងប្រយ័ត្ន បដិបត្តិឲ្យបានល្អម៉ត់ចត់ត្រឹមត្រូវទេ ទុក្ខលំបាក នឹងរឹតតែកើតឡើងច្រើនជាអនេកប្បការ បានជាព្រះសាស្តាបរមគ្រូ នៃយើង ប្រៀនប្រដៅថា *អប្បមាទេន សម្បាទេថ* អ្នកទាំងឡាយ ចូរញុំាងកិច្ចការទាំងពួងឲ្យសម្រេចដោយសេចក្តីមិនប្រមាទចុះ ។ ម៉្យាងទៀត បើមនុស្សយើង មានតែសេចក្តីប្រមាទ នឹងធ្លាក់ចុះក្នុងរណ្តៅទុក្ខកាន់តែខ្លាំងឡើងៗ ប៉ុន្តែ បើមនុស្សយើងចាប់មានសេចក្តីមិនប្រមាទវិញ យើងនឹងបានស្រាលទុក្ខជាបណ្តើរៗ ស្មើនឹងចំណែកនៃសេចក្តីមិនប្រមាទដែលយើងមាន ក្នុងទីបំផុត យើងអាចរំលត់ទុក្ខទាំងស្រុងបានពោលគឺ សម្រេចព្រះនិព្វានពិតពុំខាន បានជាព្រះពុទ្ធទ្រង់ត្រាស់ចុងក្រោយបំផុតថា “ កុំប្រមាទ“ ។

## ចាំបាច់ធ្វើអ្វីទៀត?

អ្នកខ្លះគេអាងថា គេមិនសម្លាប់សត្វ មិនលួចទ្រព្យអ្នកដទៃ មិនប្រព្រឹត្តខុសឆ្គង ប្តី ប្រពន្ធ កូនចៅ អ្នកដទៃ គេមានចាំបាច់ធ្វើអ្វីទៀត ។ ល្អជាងអ្នកដែលធ្វើអីចឹងមិនទាន់បានដែរ ប៉ុន្តែ មិនទាន់ជាប្រសើរទេ ។ ក្មេងតូចៗ វាមិនលួចទ្រព្យ មិនសម្លាប់សត្វ មិនប្រព្រឹត្តខុសឆ្គងក្នុងកាមទេ ប៉ុន្តែ ព្រះពុទ្ធមិនចាត់ថា វាមានសីលទេ ព្រោះខ្វះចេតនា ។ អំពើប្រកបដោយចេតនាឲ្យផលច្បាស់លាស់ជាង ។ អ្នកខ្លះគេថា គេសមាទានសីលហើយ សមាទាននៅផ្ទះមិនចាំបាច់ទៅវត្តទេ ។ ការសមាទានសីលមិនបង្ខំឲ្យទៅសមាទាននៅទីវត្តតែម៉្យាងទេ សមាទាននៅទីណាក៏បានដែរ ប៉ុន្តែ រឿងវត្តជារឿងដែលយើងទាំងអស់គ្នាត្រូវគិត... មានកិច្ចដែលត្រូវទៅវត្ត ឬមិនមាន បើមិនមាន មិនត្រូវទៅទេ បើមានត្រូវទៅបើអាចទៅបាន ។ តាមធម្មតា គេទៅវត្តដើម្បីធ្វើទាន រក្សាសីល ចំរើនមេត្តាភាវនា ឬធ្វើកិច្ចការផ្សេងៗ ដែលគួរធ្វើនៅទីនោះ ។ សាសនារបស់យើង វត្តរបស់យើង បើយើងមិនបដិបត្តិ មិនឧបត្ថម្ភ

[៧] *សុត្តន្តបិដក ទីឃនិកាយ មហាវគ្គ១៦/១៤៣/៣២៤ ។*

មិនថែទាំ មិនផ្សព្វផ្សាយ ត្រូវតែចប់ គួរឲ្យចប់ទេ? មិនគួរសោះឡើយ ព្រោះគ្មានសាសនាណាល្អស្មើនឹងពុទ្ធសាសនាទេ ដូចនេះត្រូវតែទៅវត្ត ត្រូវតែនាំគ្នាធ្វើសេចក្ដីល្អឲ្យច្រើន ។ យើងទៅវត្តមិនទាន់បាន ព្រោះជាប់ការងារច្រើនពេក មិនទាន់ជាទោសប៉ុន្មានទេ ប៉ុន្តែ បើយើងយល់ខុសថាការដែលយើងបានធ្វើនៅផ្ទះគឺចប់សព្វគ្រប់អស់ហើយ នេះជាកិលេស ជាអវិជ្ជាហើយ ។ បើយើងយល់ហើយប្រកាន់ថា មិនបាច់ទៅទីណាទៀតទេ ធ្វើតែនៅផ្ទះបានសព្វគ្រប់ហើយ នេះជាកិលេស គឺ ទិដ្ឋិ មានះ ហើយ ។ យើងបណ្ដែតបណ្ដោយមិនប្រឹងលះទុច្ចរិត មិនខំប្រឹងចំរើនសុចរិតជាដើម នេះជាសេចក្ដីប្រមាទហើយ ទាំងអស់នេះ សុទ្ធតែជាមេកិលេសធំៗ ។ ហេតុនេះ សូមអស់លោកអ្នកគិតគូសាជាថ្មីឲ្យទាន់ពេលវេលា កុំឲ្យការចេះដឹងរបស់ខ្លួននោះ ក្លាយទៅជាថ្នាំពិសពុល ឬជាអាវុធសម្លាប់ខ្លួនឯងឡើយ ៕

# បច្ឆិមវាចា

(វាចាចុងក្រោយបំផុតរបស់ព្រះពុទ្ធ)

ហន្ទ: អ្នកទាំងឡាយ គ្រប់រូបកាយមកអាយវ៉ា
តថាគតនឹងមតា[៨] ចាកចោលបាត់តឡូវហើយ ។
សង្ខារមិនទៀងទេ ចូរគ្នាន់គ្នេរកុំកន្តើយ
វាអន់អស់ទៅហើយ មិននៅឡើយដូចធម្មតា ។
ប្រែប្រួលម្តងបន្តិច ជាប់ជានិច្ចរាល់វេលា
យើងគេទាំងអស់គ្នា គ្មាននរណាគេចផុតបាន ។
អនិច្ចំ និង ទុក្ខា អនត្តាមានគ្រប់ប្រាណ
អ្នកក្រ ឬ អ្នកមាន ល្ងង់ ឬ ចេះមានស្មើគ្នា ។
សូម្បីទ្រព្យសម្បត្តិ វត្ថុអ្វីផងនានា
កើតឡើងក្នុងលោកា នៅនាក្រោមច្បាប់ត្រៃលក្ខណ៍ ។
ចូរនាំគ្នាសិក្សា ពិចារណាឲ្យយល់ជាក់
ច្បាស់ច្បាប់ព្រះត្រៃលក្ខណ៍ ហើយពួកអ្នកកុំក្រកាន់ ។
ឈប់យល់ថាខ្លួនអញ ត្រូវយល់ថាជាបញ្ចក្ខន្ធ
គ្មានអ្វីគួរក្តួចកាន់ ថាជាអញយើងគេឡើយ ។
ប្រកាន់បានតែទុក្ខ ឈប់ប្រកាន់បានសុខស្បើយ
ឈប់ទូលរែកពុនហើយ ដាក់វាចុះអស់ធ្ងន់ទៀត ។
ហេតុនេះអ្នកទាំងឡាយ គ្រប់រូបកាយកុំប្រមាទ
សតិខំសង្វាត លះអំពើទុច្ចរិត ។
ដោយកាយ និង វាចា បីនេះណាព្រមទាំងចិត្ត
មិច្ឆាទិដ្ឋិពិត ត្រូវតែលះបង់ចោលផង ។
ហើយនាំគ្នាចំរើន សុចរិតឲ្យហ្មត់ហ្មង
សម្មាទិដ្ឋិផង ត្រូវចំរើនឲ្យច្រើនណា៎ !
សតិកុំត្រេកអរ ក្នុងអ្វីគួរគាប់ប្រាថ្នា
កុំក្រោធខឹងទោសា ក្នុងអ្វីគួរតែប្រទូស្ត ។
កុំមានក្តីវង្វេង ក្នុងអ្វីគួរវង្វេងនោះ
សតិតាំងចំពោះ រារាំងទប់ចិត្តឲ្យបាន ។

[៨] *មតា ត្រឹមត្រូវជាឯមរណាមិនត្រូវទេប៉ុន្តែ គេចេះតែប្រើទៅ។*

កុំឲ្យចិត្តស្រវឹង ក្នុងអារម្មណ៍ពាលសាមាន្យ
ប្រព្រឹត្តដូចតិរច្ឆាន មិនសមឋានជាមនុស្សឡើយ ។
អ្នកដែលប្រមាទនោះ សូម្បីរស់ដូចស្លាប់ហើយ
ព្រោះគ្មានក្តីល្អឡើយ កើតឡើងដោយក្តីប្រមាទ ។
អ្នកដែលធ្វើល្អវិញ ចិត្តគេមិញជ្រះថ្លាស្អាត
ព្រោះគេមិនប្រមាទ សូម្បីស្លាប់ទុកដូចរស់ ។
ពាក្យនេះន័យជ្រៅណាស់ រៀនឲ្យច្បាស់សព្វទាំងអស់
សង្ខេបត្រឹមណឹងចុះ ចប់ចរចូលនិព្វានហោង ៕

## សេចក្តីស្រវឹង

ខ្ញុំនឹងថ្លាថ្លែងចែងសេចក្តី ជូនជនប្រុសស្រីឲ្យបានដឹង
រៀបរៀងរាយរាប់រឿងស្រវឹង ទុកជាដំណឹងតរៀងទៅ ។
ស្រវឹងកញ្ឆាស្រាអាភៀន ហេរ៉ូអ៊ីនញៀនពេលឥឡូវ
ជក់ផឹកឬលេបវាចូលទៅ លែងស្គាល់ខុសត្រូវម៉ែឪឯង ។
គេប្រើធ្វើអ្វីក៏ធ្វើដែរ លួចប្លន់ហួរហែរឃើញជាក់ស្តែង
ស៊ីឈ្នួលសម្លាប់ឥតកោតក្រែង ព្រមលក់ខ្លួនឯងបម្រើគេ ។
ស្រវឹងប្រុសស្រីក្តីស្នេហា ជាប់ចិត្តប្រាថ្នារឿងកាមេ
មិនយល់ប្តីកូនប្រពន្ធគេ រិះរេធ្វើម៉េចខាងតែបាន ។
មិនខ្លាចផលបាបអកុសល ដែលផ្តល់ទុក្ខសោកមកដល់ប្រាណ
ចុះនរកប្រេតតិរច្ឆាន បាបបុណ្យប៉ុន្មានលែងខ្វីគិត ។
ស្រវឹងយសសក្តិប្រាក់អំណាច អត់ខ្លាចដល់រាស្ត្រជាម្ចាស់សិទ្ធិ
ធ្វើកិច្ចការរដ្ឋស្រេចតែចិត្ត ប្រយោជន៍ជាតិពិតបាត់បង់អស់ ។
នរណាហ៊ានថាសម្លាប់ចោល សូម្បីស្រមោលអត់ឃើញសោះ
ទ្រព្យរដ្ឋយកលក់ឥតស្រណោះ សម្បត្តិជាតិអស់ស្ទើគ្មានសល់ ។
រាស្ត្រត្រូវក្រោកឡើងអួសទម្លាក់ ពួកអ្នកស្រវឹងអកុសល
ទុកយូរទៅទៀតនាំសល់រ៉ល់ ជាតិលិចលង់ដល់កែលែងកើត ។
ស្រវឹងទ្រព្យធននិងពូជពង្ស ថាវង្សត្រកូលខ្លួនល្អឆើត
ពូជគេឯទៀតសុទ្ធមិនកើត ល្អឆើតសុទ្ធតែពូជពង្សខ្លួន ។
តាមពិតគឺពូជពួកខ្លួនដែរ កាត់ទឹកដីខ្មែរ ឲ្យសៀមយួន
ជញ្ជក់ឈាមរាស្ត្ររបស់ខ្លួន បានពេញសំនួនមើលងាយគ្នា ។

ស្រវឹងនិងលេងបៀរអាប៉ោង កាស៊ីណូផងល្បែងនានា
ស្រវឹងជ្រប់ជ្រុលចោលការងារ ចាញ់អស់ទ្រព្យាដើរលួចប្លន់ ។
ស្រវឹងវ័យថាខ្លួននៅក្មេង គិតតែរឿងលេងគ្មានបង្អន់
ស្រវឹងអត់រោគថាខ្លួនគ្រាន់ មិនទាន់ប្រញាប់ធ្វើការងារ ។
ស្រវឹងថាខ្លួនមិនទាន់ស្លាប់ ជីវិតស្ថិតជាប់តាមពូជធារ
កុំអាលធ្វើទាន សីល ភាវនា ពួកយើងរាល់គ្នាមិនទាន់ចាស់ទេ ។
ខ្លះស្រវឹង ទាន សីល ភាវនា ផងយើងរាល់គ្នាគ្រាន់ជាងគេ
គ្មាននរណាស្មើនឹងយើងទេ ប្រសើរលើសគេគឺពួកយើង ។
ស្រវឹងទាំងលោកទាំងបាសក ថោកទាបអាក្រក់មិនថ្កុំថ្កើង
ជាតិនិងសាសនារបស់យើង រុងរឿងមិនរួចព្រោះស្រវឹង ។
ស្រវឹងហ្នឹងហើយគឺប្រមាទ លោកនាថសម្ដែងទុកអីចឹង
នាំគ្នាប្រមាទច្រើនម្លឹងៗ ជាតិសាសន៍យើងហ្នឹងសូន្យពុំខាន ។
ឈប់ប្រមាទទៀតជាតិថ្កើងថ្កាន សាសនាយើងបានរុងរឿងអើយ ៕

## អាការរបស់អ្នកប្រមឹក

សម្បើមយក្ស អារក្សសន្ធំ រងំចិត្ត អាណិតខ្លួន ស្ងួនចំណី សម្ដីខ្មោច អសោចកើ្ដ ចង្អោរបក់ បង្ហក់ទឹក ដេកវាស់ព្រឹក ដាស់លែងភ្ញាក់ ដាក់មឈុស អូសទៅកប់ ងាប់តាយហោង ។

សេចក្ដីពន្យល់ ៖ ផឹក១កែវមុនដំបូងបែបសម្បើមឃើញដំរីស្មានថាកណ្ដុរ.. ផឹកច្រើនកែវយូរ ទៅក្ដៅដូចខ្មោចសន្ធំនិយាយរងំតែម្នាក់ឯងដូចជាអាណិតខ្លួន គេយកចំណីទៅជូនហូបមិនសូវរកីត និយាយសម្លេងខ្សាវៗ ដូចខ្មោចក្លិនអសោច ក្អួតចង្អោរខោរបូតរហូតដល់សន្លប់ គ្មានផ្ចិតយកចង្អោរបង់ ផឹកទឹកមិនកើតជួយបន្តក់តិចៗដេកវាស់ព្រឹក ដាស់លែងភ្ញាក់ ដាក់មឈូស អូសទៅកប់ ងាប់តាយហោង ។

## សុភាសិតខ្លីៗ

ប្រតិនទិនប្រចាំឆ្នៃនៅវត្តពោធិវង្ស ប្រទេសបារាំងត្រង់កន្លែងសល់ចន្លោះៗ មានចុះពុទ្ធភាសិតខ្លះ បុរាណភាសិតខ្លះ ភាសិតតែងឡើងថ្មីៗខ្លះ ។ ឥឡូវខ្ញុំដកស្រង់យកភាសិតតែងឡើងថ្មីៗខ្លះនោះមកចុះរក្សាទុកក្នុងកូនសៀវភៅនេះ ។

រួមគ្នាជាតិរស់ ឈ្លោះគ្នាជាតិស្លាប់
ជាតិចុះអន់អាប់ ព្រោះអ្នកដឹកនាំ ។

***

ជួយយួនជាតិវិនាស ជួយរាស្ត្រជាតិរុងរឿង ។

***

ជាតិលូតលាស់ ដោយសារសាមគ្គី
ជាតិខ្ទេចខ្ទី ដោយសារការបាក់បែក ។

***

ឈ្នះដើម្បីខ្លួន ឈ្នះដើម្បីយួន ឬជាតិដទៃ
ឈ្នះជាតិលិចលង់ ឈ្នះសែនចង្រៃ ឈ្នះល្អប្រពៃ
ឈ្នះដើម្បីខ្មែរ ។

***

អ្នកធ្វើនយោបាយផ្តាច់ការ ដឹកនាំរដ្ឋាទៅរកទុក្ខ
គង់តែទេព្តាបរាមុខ សោយទុក្ខទាន់ហន់គេចមិនផុត ។

***

កុំខ្លាំងពូកែតែគ្នាឯង ត្រូវចេះគិតក្រែងគិតវែងឆ្ងាយ
ខ្មែរយើងពីដើមសុខសប្បាយ ដីធំទូលាយព្រោះសាមគ្គី ។

***

ធ្វើនយោបាយបំបែកបក្ស ចង់បានយសសក្តិប្រាក់ខែចាយ
គេស្គាល់មារយាទគេទាត់ឆ្ងាយ កើតក្តៅក្រហាយព្រោះក្តីក្បត់ ។

***

ទាន់គេខាងហូបនិងខាងប្រើ ពិតពុំប្រសើរខ្មែរគួរគិត
បើយើងទាន់គេខាងផលិត នោះពិតជាខ្មែរស្នេហាជាតិ ។

***

ស្រុកខ្មែរស្រុកធ្វើកសិកម្ម ស្រូវបន្លែដាំមិនគ្រប់ស៊ី
រវល់តែឈ្មោះគ្នាវក់វី រាស្ត្រអត់អីស៊ីទិញសៀមយួន ។
សៀមយួនគេធ្វើនាំលក់ចេញ គេបានចំណេញតែរៀងខ្លួន
ជាតិគេធំធាត់រឹងមាំមួន បើកភ្នែកគ្រលួងសម្លក់ខ្មែរ ។

***

បំផុសគ្នានិយាយខាងផលិត កុំគិតនិយមតែបរិភោគ ។

***

អ្នកស្រឡាញ់ជាតិ កុំឃាតពីសាសនា
អ្នកអត់ធម៌អាថ៌ កុំនឹកថាដឹកនាំកើត ។
បើស្រឡាញ់ជាតិ កុំគិតលោភលន់
បើស្រឡាញ់ធន កុំគិតធ្វើធំ

ធ្វើមេដឹកនាំ កុំចងគំនុំ
បើចង់ជួបជុំ ត្រូវយុត្តិធម៌ ។

***

គេឈ្លានពានមកមិនតវ៉ា វាយសិស្សសាលាឲ្យបិទមាត់
គ្រប់គ្រងបែបហ្នឹងមុខជាភ្លាត់ បាត់ទឹកដីរដ្ឋពិតពុំខាន ។

***

កុំមានចិត្តលលើ ពឹងក្រពើឲ្យចម្លង
កុំកាច់អួសរបង វាំងចំណារឯអាត្មា ។
កុំគិតពឹងសៀមមយួន ថាមាំមួនជាងខេមរា
ត្រូវខ្មែរដូចគ្នា ទើបកម្ពុជា ផុតទុក្ខភ័យ ។
ទំនៀមទម្លាប់វប្បធម៌ខ្មែរ កុំនាំគ្នាកែដោយល្ងិតល្ងង់
គំនិតមិនដល់នាំលិចលង់ វប្បធម៌សូន្យសុងជាតិរលាយ ។

***

កុំសុខសប្បាយតែគ្នាឯង ត្រូវចេះគិតក្រែងដល់គ្នីគ្នា
ខ្មែរភាគច្រើនណាស់ទុក្ខវេទនា ត្រូវខំជួយគ្នាឲ្យសុខផង ។

***

គេស្រឡាញ់ជាតិរឹតតែមាន មាសប្រាក់ធនធានរាប់មិនអស់
ឯងស្រឡាញ់ជាតិគ្មានអីសោះ តើមានទំនាស់មកពីអ្វី ?

***

ខ្ជះខ្ជាចបាក់ស្បាតដាំដើមគរ ដើរអង្គុយឈរបិទមាត់ឈឹង
ធ្វើម្តេចកូនចៅនឹងយល់ដឹង អំពើបែបហ្នឹងជាតិរលាយ ។

***

កុំជោរចង់បានពាក្យសរសើរ ពាក្យនោះទុកស្មើថ្នាំពិសពុល
ចូលទៅពេលណាចិត្តងប់ងុល វក់វង្វេងជ្រុលលែងដឹងពិត ។

***

ជនមិនមាននាយកក៏វិនាស នាយកច្រើនពាសវិនាសដូចគ្នា
នាយកល្ងិតល្ងង់មិនគង់ទ្រព្យា ត្រូវរួបរួមគ្នាជួយគិតដោះស្រាយ ។

***

ទ្រព្យសម្បត្តិជាតិគិតតែលក់ គំនិតគម្រក់ចង់បានប្រាក់
ងងិតងងល់ដូចមនុស្សខ្វាក់ មើលមិនឃើញជាក់ហេតុវិនាស ។

***

នាំគ្នាទៅកាន់ការបាក់បែក ហើយខំប្រឹងប្រែងស្រែកថាចំរើន

ទោះជួយយ៉ាងណាក៏មិនកើន    ទុក្ខកើតរន្លើនច្រើនឥតអាក់ ។

***

ជូនពរឆ្នាំថ្មី    បងប្អូនប្រុស្រី    បានជោគជយា    អាយុ    វណ្ណះ
សុខះ    ពលា    កើតមានគ្រប់គ្នា    កុំបីឃ្លៀងឃ្លា ។
កុំរស់តែឯង    ត្រូវចេះចែកបែង    ដល់គេឯទៀត    កើតមកជាខ្មែរ
ពូកែមារយាទ    គិតប្រទេសជាតិ    និងព្រះសាសនា ។

***

ការជាតិការខ្មែរទាំងអស់គ្នា    ម្តេចគេធ្វើជារបស់ខ្លួនខុសខូច
ខាតចាញ់បោកយួន    គេប្រាប់ផ្ទួនៗ ត្រូវតែស្តាប់ ។

***

បើកាន់សាសនាកុំភ្លេចជាតិ    ព្រោះជាតិជាលំនឹងសាសនា
បើជាតិលិចលង់បង់ទៅវ៉ា    សាសនាតាំងនៅដូចម្តេចបាន ។

***

ស្រុកខ្មែរស្រុកធ្វើកសិកម្ម    រាស្ត្រខិតខំដាំសព្វបន្លែ
បើរដ្ឋមិនជួយគាំទ្រខ្មែរ    បន្លែបរទេសចូលពេញស្រុក ។

***

អ្នកគំនិតខ្លី    មិនគិតទឹកដី    គិតតែអាត្មា
នៅស្ងៀមព្រងើយ    ដូចអត់បញ្ញា    ទុរជនអសារ
គួរកំចាត់ចោល ។
បើស្រឡាញ់ជាតិ    កុំឃ្លាតពីធម៌    បើស្រឡាញ់ល្អ
កុំល្អតែម្នាក់ឯង    បើស្រឡាញ់ជាតិ    កុំស្តាយតំណែង
ត្រូវហ៊ានលាលែង    ទុកឲ្យជាតិរស់ ។

***

បើស្រឡាញ់ធម៌    កុំអរកុំអន់    ចិត្តស្មើពេកពន់
ពេលជួបអារម្មណ៍    ត្រូវមានសតិ    ទប់ចិត្តឲ្យមាំ
ខិតខំសន្សំ    បានធម៌ពិតហោង ។

***

ចេះឯងឲ្យក្រែងចេះគេ    ចេះគិតគ្នាន់គ្នេរ    ដល់ចេះគេផង ។
ចេះច្រើនគ្នាល្អកន្លង    សាកសួរសាសង    សន្សំសាងខុស ។
ថ្ងៃយប់នាំយក    អាយុសត្វលោក    ទាំងប្រុសទាំងស្រី
ឥតបង្អង់ឈប់    មួយនាទីអី    បើមិនលកលៃ
ស្លាប់បង់អសារ ។

ភ្ញាក់ឡើងក្រោកឡើង កុំនៅចចើង ជាប់ចិត្តកាមា
ត្រូវរៀនសមថៈ វិបស្សនា ដឹកនាំអាត្មា
ទៅរកក្តីសុខ ។

***

ទៅវត្តគ្រាន់តែជាពិធី មិនគិតសំភីខំរកធម៌
អប់រំខ្លួនប្រាណឲ្យបានល្អ ទោះវត្តណាក៏ជួយមិនបាន ។
ទៅដល់ស្រះទឹកហើយមិនងូត ស្រូតរូតក្រេបផឹកចំអែតប្រាណ
តើស្រះទឹកណាជួយអ្នកបាន ឲ្យស្អាតឆ្អែតប្រាណជួសខ្លួនអ្នក ។

***

ផ្លូវទៅស្ថានសួគ៌ដើរទក់ៗ ផ្លូវទៅនរកដើរខូងដី
ទៅកាន់សាសនាគ្នាពីរបី ទៅកាន់ស្រាស្រីគ្នារាប់រយ ។

***

រៀនធម៌ត្រូវតែបដិបត្តិ កុំហាត់ត្រឹមចេះចាំសូត្របាន
យើងគេបានក្តីសុខក្សេមក្សាន្ត ព្រោះបានបដិបត្តិមិនមែនសូត្រ ។

***

បើកាន់សាសនាកុំថាតែមាត់ ត្រូវចូលទៅវត្តបដិបត្តិធម៌ផង
ជួយថែរក្សានិពន្ធចម្លង ផ្សព្វផ្សាយធម៌ផងទើបបានប្រសើរ ។

***

អប់រំចិត្តឲ្យស្ងប់ កុំឲ្យស្អប់កុំស្រឡាញ់
ឧបេក្ខាចិត្តវិញ បានចំណេញប្រសើរជាង ។

***

ព្រះពុទ្ធនាំគេឲ្យបដិបត្តិ មិនដែលហ្វឹកហាត់ឲ្យបន់ស្រន់
បើអ្នកចូលចិត្តតែបំណន់ ទៅបនអ្នកតាឯណាចុះ ។

***

បើស្រឡាញ់ខ្លួនឲ្យស្ងួនព្រះធម៌ បើស្រឡាញ់ល្អឲ្យស្ងួនខន្តី ។

ដោយ ភិក្ខុ ងិន ភេន ឥន្ទប្បញ្ញោ

***

សីលធម៌មិនត្រឡប់មក សកលលោកនឹងវិនាស ។

***

ចិត្តមនុស្សអត់សីលធម៌ កុំត្រេកអររកសន្តិភាព ។

***

សភាអត់ជនសប្បុរស កុំសង្ឃឹមសោះថាជាតិសុខសាន្ត ។

***

ទូកល្អមានមិនគិតជិះ បែរជាប៉ុនប៉ងជិះតែទូកលិច
ចង់អភិវឌ្ឍន៍ឲ្យសម្រេច បែរជាកំទេចមនុស្សល្អ ។

***

ពេលបានមកបានឲ្យត្រឹមត្រូវ ទើបមិនក្លាយទៅជាទុក្ខហោង
ពេលស្តាប់ស្តាប់កុំឲ្យសៅហ្មង នឹងបានសុខផងល្អល្អះក្រៃ ។

***

ខ្មែរបានសង្ឃឹមថា អ្នកស្នេហាស្ងួលះបងប្រាណ
នោះមុខជានឹងបាន ជាតិថ្កើងថ្កានល្អត្រចះ ។
ឥឡូវខុសបំណង បែរជារងឯកម្មក្រាស់
ព្រោះខ្មែរចាញ់បោកប្រាស់ អ្នកស្នេហាអកុសល ។

***

រឿងអាក្រក់មិនត្រូវធ្វើ គួរអើពើតែរឿងល្អ ។

***

មនុស្សរមាស់មាត់ ពិបាកឃាត់ឲ្យនៅស្ងៀម
ព្រោះចិត្តនៅជាំចៀម ស្ងៀមមិនកើតព្រោះរមាស់ ។

***

សុខឬទុក្ខកើតមកពីចិត្ត ព្រោះតែកិតខុសពេលផស្សា
បានជាញាប់ញ័រអន្ទះសា ឡើងចុះឆ្វេឆ្វាតាមលោកធម៌ ។

***

សភាដែលអត់សប្បុរស តែងខ្វះការស្មោះត្រង់ដល់ជាតិ ។

***

នយោបាយលាយដោយសីលធម៌ ជាតិរស់បានល្អសុខសប្បាយ
គ្មានសីលធម៌ធ្វើនយោបាយ ជាតិនឹងប្រែក្លាយជាសាបសូន្យ ។

***

បើឥតយុត្តិធម៌ សីលធម៌ កុំខំអង្វរសុំសន្តិភាព
លុះតែគុណធម៌ពេញរូបភាព ទើបសុខសន្តិភាពប្រាកដហោង ។
ព្រោះអំណាចវត្ថុនិយមក្រៃ ទើបនយោបាយគិតតែប្រយោជន៍
លែងគិតសីលធម៌ប្រទេសហិចហោច គួរឲ្យអាណោចដល់ប្រជារាស្ត្រ ។

***

បំផុសគំនិតជួយសាងជាតិ កុំគិតតែវាតប្រយោជន៍ផ្ទាល់ខ្លួន
យើងខ្វះអ្នកជួយជាតិឲ្យមាំមួន ច្រើនអ្នកកប់ខ្លួនពួនស៊ីជាតិឯង ។

***

ការជួយសង្គ្រោះអ្នកដទៃ ទុកជាកម្រៃនៃជីវិត
លះបង់ប្រយោជន៍ផ្ទាល់ខ្លួនពិត ស៊ូប្តូរជីវិតជួយជាតិសាសនា ។

***

អ្នកស្នេហាជាតិគ្រប់ទិសទី ច្រើនតែវក់វីកើបប្រយោជន៍
មានទ្រព្យមានសក្តិក្លិនអសោច គួរឲ្យអាណោចជាតិខេមរា ។

***

នត្ថិ បញ្ញាសមា អាភា ព្រះភគវាទ្រង់សម្តែងថា
គ្មានពន្លឺអ្វីភ្លឺស្មើបញ្ញា ត្រូវប្រើបញ្ញាគ្រប់គ្រងការងារ ។

***

នត្ថិ តណ្ហាសមា នទី ព្រះមុនីទ្រង់ទេសនាទូន្មាន
ស្ទឹងស្មើដោយតណ្ហាពិតជាគ្មាន អ្នកស្គាល់ប្រមាណទើបបានសុខ ។

***

នត្ថិ អត្តសមំ បេមំ កុំស្រឡាញ់ខ្លាំងជាងស្រឡាញ់ខ្លួន
រួមគ្នាសាងជាតិឲ្យបានមាំមួន ទើបបានរួចខ្លួនពីគ្រោះអាសន្ន ៕

ដោយ ព្រះមហាបុណ្យ សគុណ

**អប្បមាទោ អមតំ បទំ** *សេចក្តីមិនប្រមាទជាផ្លូវនៃសេចក្តីមិនស្លាប់។*
**បមាទោ មច្ចុនោ បទំ** *សេចក្តីប្រមាទជាផ្លូវនៃសេចក្តីស្លាប់។*

ខ្ញុំសូមឧទ្ទិសចំណែកបុណ្យកុសលនេះ ប្រគេន ជូន ចំពោះវិញ្ញាណក្ខន្ធនៃលោកអ្នកដ៏មានគុណទាំងឡាយ មានគ្រូឧបជ្ឈាយាចារ្យ និង មាតាបិតា ជាដើមផង ព្រមទាំងញាតិមិត្តទាំងឡាយផង ។ សូមលោកអ្នកដ៏មានគុណជាដើមនោះ អនុមោទនាទទួលយកនូវឥដ្ឋមនុញ្ញផលជាទីគាប់ចិត្ត តាមសេចក្តីជ្រះថ្លារៀងៗខ្លួន កុំបីអាក់ខានឡើយ ។

# ចប់

សៀវភៅដែលនិពន្ធដោយ

**ព្រះមហាថេរៈធិន ភេន ឥន្ទប្បញ្ញោ**

អតីតព្រះមេគណក្រុងភ្នំពេញ វត្តស្វាយពពែ

| | |
|---|---|
| ១-មង្គលសូត្តគាថា និង បរាភវសូត្ត | ឆ្នាំ ១៩៩២ |
| ២-ពុទ្ធោវាទសង្ខេប | ឆ្នាំ ១៩៩៤ |
| ៣-ប្រស្នាអដ្ឋង្គិកមគ្គ | ឆ្នាំ ១៩៩៤ |
| ៤-សមថសង្ខេប | ឆ្នាំ ១៩៩៤ |
| ៥-វិបស្សនាសង្ខេប | ឆ្នាំ ១៩៩៤ |
| ៦-កំណាព្យរស្មីជីវិត | ឆ្នាំ ១៩៩៥ |
| ៧-ខន្ធ ៥ | ឆ្នាំ ១៩៩៦ |
| ៨-ឧបករណ៍វិបស្សនា | ឆ្នាំ ១៩៩៨ |
| ៩-សេចក្តីមិនប្រមាទ | ឆ្នាំ ២០០០ |
| ១០-កម្មផល | ឆ្នាំ ២០០០ |
| ១១-ពុទ្ធសាសនារុងរឿង ឬរោយរៀវ | ឆ្នាំ ២០០២ |
| ១២-ប្រាថ្នាសមថ និង វិបស្សនា ភាគ ១,២,៣, | ឆ្នាំ ២០០២ |
| ១៣-បាប និង បុណ្យ | ឆ្នាំ ២០០៣ |
| ១៤-កើត ស្លាប់ | ឆ្នាំ ២០០៤ |
| ១៥-ដៃគូអ្នកកាន់ពុទ្ធសាសនា | ឆ្នាំ ២០០៤ |
| ១៦-យើងអាចចំរើនអាយុបាន និងកំណាព្យ | ឆ្នាំ ២០០៦ |
| ១៧-ហិនយាន មហាយាន | ឆ្នាំ ២០០៧ |
| ១៨-ខ្មែរមានពូជ | ឆ្នាំ ២០០៧ |

សៀវភៅទាំងប៉ុន្មាននេះ  តាមពិតគឺគ្រាន់តែជាការបានស្គាល់របស់ខ្ញុំខ្លះៗ តែប៉ុណ្ណោះ  បើតាមខ្ញុំដឹងគឺលោកសរសេរនិងបោះពុម្ពដើម្បីចែកជាធម្មទានជារៀងរាល់ឆ្នាំ អាចនិយាយបានថា  នៅមានច្រើនជាងនេះទៀតដែលយើងមិនអាចដឹងអស់បាន។